Cowater International

Australian Aid

# កម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលីសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់
(CAP-RED)

## សេចក្តីប្រកាសផ្តល់ជំនួយដល់ប្រតិបត្តិករទឹកស្អាតឯកជនក្នុង
## "តំបន់ទទួលប្រកាសអនុញ្ញាតផ្ទាល់"
## ជុំទីមួយ

### ១. គោលបំណង និងយុទ្ធសាស្ត្រនៃកម្មវិធី

កម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ ឬហៅកាត់ថា CAP-RED គឺជាកម្មវិធីថ្មីមួយ ដែលទទួលបានមូលនិធិទាំងស្រុងពីក្រសួងកិច្ចការបរទេស និងពាណិជ្ជកម្មរបស់អូស្ត្រាលី (DFAT)។ កម្មវិធីនេះមានរយៈពេលប្រាំឆ្នាំ និងមានសក្តានុពលក្នុងការពន្យារយៈពេលបីឆ្នាំបន្ថែមទៀត។ កម្មវិធី CAP-RED នឹងធ្វើការនៅក្នុងវិស័យចំនួនបី៖ វិស័យកសិកម្ម វិស័យពាណិជ្ជកម្ម និងវិនិយោគ និងវិស័យសេវាហេដ្ឋារចនាសម្ព័ន្ធ ដោយសំសៅជួយដល់ប្រទេសកម្ពុជាក្នុងការជម្រុញ កំណើនសេដ្ឋកិច្ច ប្រកបដោយនិរន្តរភាព ភាពធន់ និងបរិយាបន្ន។

កម្មវិធី CAP-RED នឹងបន្តផ្តល់ការគាំទ្រទៅដល់ប្រតិបត្តិករ និងអ្នកវិនិយោគផ្គត់ផ្គង់ទឹកស្អាតតាមបំពង់តាមគំរូស្រដៀងគ្នាទៅនឹង កម្មវិធីការវិនិយោគក្នុងកម្មវិធីហេដ្ឋារចនាសម្ព័ន្ធ(3i) ដែលបានអនុវត្តកាលពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០២២។ កញ្ចប់ផ្តល់ជំនួយរួមមានជំនួយវិនិយោគឥតសំណង និងជំនួយបច្ចេកទេស ដើម្បីជួយប្រតិបត្តិករ និងអ្នកវិនិយោគ ក្នុងការសាងសង់និងពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមបំពង់នៅក្នុងតំបន់សេវាកម្ម ដែលខ្វះភាពទាក់ទាញក្នុងការបណ្តាក់ទុនវិនិយោគក្នុងរយៈពេលឆាប់ៗខាងមុខនេះ ប្រសិនបើគ្មានជំនួយ។

កម្មវិធី CAP-RED នឹងអនុវត្តនីតិវិធីយ៉ាងម៉ឹងម៉ាត់សម្រាប់ការជ្រើសរើសប្រតិបត្តិករ និងអ្នកវិនិយោគសម្រាប់ការផ្តល់ជំនួយ។ កម្មវិធីក៏នឹងមានការដាក់បញ្ចូលនូវការគិតគូរអំពីសមភាពយេនឌ័រ លើកកម្ពស់ពិការភាព និងបរិយាបន្នសង្គម នៅក្នុងគ្រប់ទិដ្ឋភាពដែលអាចធ្វើបាននៃដំណើរការនៃការផ្តល់ជំនួយនេះ។

CAP-RED is funded by the Australian Government and implemented by Cowater International.

.

Address: The iCON Professional Building, 216 Preah Norodom Blvd (41), Phnom Penh
Email: info@capred.org
Tel: 012 817 829

## ២. ជំនួយសម្រាប់វិស័យទឹក

ជុំជំនួយទីមួយនេះនឹងធ្វើការផ្តល់ថវិការជំនួយដល់ ប្រតិបត្តិករទឹកស្អាតឯកជនដែលទទួលបានប្រកាសអនុញ្ញាត២០ឆ្នាំ ឬអ្នកវិនិយោគដែលបានទទួលលិខិតអនុញ្ញាតដើម្បីធ្វើការការសិក្សាសមិទ្ធិលទ្ធភាពពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧ.វ.ប.ន.)។

កម្មវិធី CAP-RED នឹងផ្តល់ការគាំទ្រចំនួនបី ប្រភេទដល់ ប្រតិបត្តិករទឹកស្អាតឯកជន និងអ្នកវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់៖

ក) ***ការគាំទ្រសម្រាប់ការសិក្សាស្រាវជ្រាវ និងធ្វើផែនការ៖*** ការផ្តល់ជំនួយសម្រាប់សកម្មភាពដូចជាការរៀបចំការសិក្សាសមិទ្ធិលទ្ធភាព ផែនការសាងសង់ ការរចនាហេដ្ឋារចនាសម្ព័ន្ធ និងផែនការវិនិយោគរយៈពេលប្រាំឆ្នាំ។ ជំនួយបច្ចេកទេសអាចត្រូវបានផ្តល់ដោយបុគ្គលិក ឬទីប្រឹក្សារបស់ CAP-RED ឬវាអាចត្រូវបានផ្តល់ដោយភាគីទីបីក្រោមការផ្តល់មូលនិធិដោយ CAP-RED ។

ខ) ***ជំនួយផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖*** ការផ្តល់ទំនួយឥតសំណងសម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត ទៅដល់ប្រតិបត្តិករ ឬអ្នកវិនិយោគតាមរយៈ កិច្ចព្រមព្រៀងផ្តល់ជំនួយបដិភាពជាមួយកម្មវិធី CAP-RED។

គ) ***ជំនួយសម្រាប់ការតភ្ជាប់បណ្តាញ៖*** ប្រាក់ឧបត្ថម្ភសម្រាប់ការតភ្ជាប់បណ្តាញដល់គ្រួសារដែលមានប័ណ្ណក្រីក្រ សាលារៀន មណ្ឌលសុខភាព និងអ្នកទទួលផលផ្សេងៗដែលកំណត់។ បញ្ជីឈ្មោះរបស់អ្នកទទួលផល ពីជំនួយតំណបណ្តាញ នឹងត្រូវបានផ្តល់ជូនដោយ CAP-RED។

កម្មវិធី CAP-RED កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីគាំទ្រដល់ប្រតិបត្តិករទឹកស្អាតឯកជន និងអ្នកវិនិយោគ ដើម្បីធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធទឹកស្អាតតាមបំពង់របស់ពួកគេមានគុណភាពស្របទៅតាមស្តង់ដារនៃប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាតនៅក្នុងប្រទេសកម្ពុជា។

## ៣. វិធីសាស្ត្រផ្តល់ជំនួយ

លក្ខខណ្ឌសំខាន់ៗសម្រាប់ការផ្តល់ជំនួយគឺ៖

ក) ប្រតិបត្តិករ ឬអ្នកវិនិយោគត្រូវចូលរួមបដិភាព ក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត។ ជាទូទៅប្រតិបត្តិករ ឬអ្នកវិនិយោគត្រូវចូលរួមបដិភាគភាគច្រើននៃទំហំវិនិយោគសរុប។

ខ) កម្មវិធី CAP-RED នឹងមិនតម្រូវឱ្យមានការសងថវិកាត្រលប់មកវិញទេ។

CAP-RED is funded by the Australian Government and implemented by Cowater International.

.

Address: The iCON Professional Building, 216 Preah Norodom Blvd (41), Phnom Penh
Email: info@capred.org
Tel: 012 817 829

គ) ប្រតិបត្តិករទឹកស្អាត ឬអ្នកវិនិយោគត្រូវទទួលខុសត្រូវលើការសាងសង់គម្រោងទាំងមូល ប្រតិបត្តិការ ការថែទាំ ជួសជុល និងការរុះរើ (ការបិទឈប់ដំណើរការ) នៃហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត តាមបំពង់នេះនាពេលអនាគត។

ឃ) កម្មវិធី CAP-RED ផ្តល់ជំនួយដល់អាជីវកម្មដើម្បីធ្វើឱ្យការវិនិយោគមានភាពទាក់ទាញ ហើយដែលពុំមិនអាចកើតឡើងដោយខ្លួនឯងបានក្នុងពេលអនាគតដ៏ខ្លីខាងមុខ។

ង) កម្មវិធី CAP-RED នឹងទូទាត់ថវិកាជំនួយជូនប្រតិបត្តករ ឬអ្នកវិនិយោគតែនៅពេលមានការបញ្ចប់សមិទ្ធផលផលជាក់លាក់ណាមួយនៃហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត។ សមិទ្ធផល និងចំនួនទឹកប្រាក់ជំនួយទូទាត់ទាំងនេះ នឹងត្រូវបានបញ្ជាក់នៅក្នុងកិច្ចសន្យា។

ច) កម្មវិធី CAP-RED នឹងធ្វើការពិនិត្យមើលអំពីភាពស្របច្បាប់ និងត្រួតពិនិត្យផលប៉ះពាល់បរិស្ថាន ហើយនឹងធ្វើការគាំទ្រតែក្រុមហ៊ុនណាដែលមានកេរ្តិ៍ឈ្មោះល្អ និងមានប្រវត្តិប្រតិបត្តិការត្រឹមត្រូវតែប៉ុណ្ណោះ។

## ៤. ដំណើរការគ្រប់គ្រងជំនួយ

ដំណើរការគ្រប់គ្រងជំនួយ មានដំណាក់កាលបន្តបន្ទាប់ដូចខាងក្រោម៖

| សកម្មភាព |
| --- |
| **ការប្រកាសផ្តល់ជំនួយ**<br>• កម្មវិធី CAP-RED ប្រកាសស្វែងរកការចាប់អារម្មណ៍ស្នើសុំជំនួយពី ប្រតិបត្តិករទឹកស្អាតឯកជន និងអ្នកវិនិយោគដែលចាប់អារម្មណ៍ទាំងអស់។ ការប្រកាសស្វែងរកការចាប់អារម្មណ៍ស្នើសុំជំនួយនេះនឹងត្រូវចុះផ្សាយក្នុងកាសែតខ្មែររបស់កម្ពុជា និងនៅលើគេហទំព័ររបស់ សមាគមផ្គត់ផ្គង់ទឹកស្អាតកម្ពុជា។ លើសពីនេះ ក្រុមការងារ CAP-RED នឹងសាកសួរ ព័ត៌មានលម្អិតអំពីប្រតិបត្តិករទឹកស្អាតឯកជនដែលបានចុះបញ្ជីនៅមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃ**ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង** និង**ខេត្តតាកែវ** ហើយបន្ទាប់មកទូរស័ព្ទទៅពួកគេដោយផ្ទាល់ ហើយសុំឱ្យពួកគេផ្តល់ព័ត៌មានអំពីក្រុមហ៊ុន។ កម្មវិធី CAP-RED លើកទឹកចិត្តឱ្យទាំងភរិយា និងស្វាមីក្នុងការចូលរួមសិក្ខាសាលាផ្តល់ព័ត៌មានអំពីជំនួយ។ |

CAP-RED is funded by the Australian Government and implemented by Cowater International.

.

Address: The iCON Professional Building, 216 Preah Norodom Blvd (41), Phnom Penh
Email: info@capred.org
Tel: 012 817 829

| សកម្មភាព |
|---|
| • ប្រតិបត្តិករទឹកស្អាត និងអ្នកវិនិយោគដែលចាប់អារម្មណ៍គួរចុះឈ្មោះចូលរួម សិក្ខាសាលាស្តីពីការផ្តល់ជំនួយ តាមរយៈ info@capred.org ឬ ទូរសព្ទ័លេខ ០១២ ៨១៧ ៨២៩។<br>• ប្រតិបត្តិករ និងអ្នកវិនិយោគអាចចូលរួមសិក្ខាសាលាស្តីពីការផ្តល់ជំនួយនៅកាលបរិច្ឆេទ និងទីតាំងខាងក្រោម៖<br>  ▪ មន្ទីឧ.វ.ប.ន. ខេត្តកំពង់ធំ ថ្ងៃទី **១១ ខែ តុលា ឆ្នាំ ២០២២** ម៉ោង 0៩:00 ព្រឹក។<br>  ▪ មន្ទីឧ.វ.ប.ន. ខេត្តកំពង់ឆ្នាំង ថ្ងៃទី **១១ ខែ តុលា ឆ្នាំ ២០២២** ម៉ោង 0៩:00 ព្រឹក។<br>  ▪ មន្ទីឧ.វ.ប.ន. ខេត្តតាកែវ ថ្ងៃទី **១១ ខែ តុលា ឆ្នាំ ២០២២** ម៉ោង 0៩:00 ព្រឹក។<br>• ប្រតិបត្តិករទឹកស្អាត និងអ្នកវិនិយោគត្រូវបំពេញ និងបញ្ជូនពាក្យស្នើសុំជំនួយឱ្យបានត្រឹម **ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២២។**<br>• កម្មវិធី CAP-RED នឹងវាយតម្លៃពាក្យស្នើសុំជំនួយទាំងអស់ ។ ប្រតិបត្តិករ និងអ្នកវិនិយោគត្រូវបំពេញតាមលក្ខខណ្ឌចូលរួមទាំងអស់ដែលបានកំណត់ក្នុង ផ្នែកទី៥ ស្តីពី"លក្ខខណ្ឌក្នុងការចូលរួម"។ |
| **ការសិក្សាសមិទ្ធិលទ្ធភាពបឋម** |
| • កម្មវិធី CAP-RED នឹងធ្វើការជិតស្និទ្ធជាមួយប្រតិបត្តិករ និងអ្នកវិនិយោគដែលត្រូវលក្ខខណ្ឌចូលរួម ដើម្បីធ្វើការសិក្សាសមិទ្ធិលទ្ធភាពបឋម ។ ដំណាក់កាលនេះ ក្រុមការងារនឹងផ្ទៀងផ្ទាត់លក្ខខណ្ឌចូលរួមទាំងអស់ដែលចែងក្នុងផ្នែកទី៥ ធ្វើការរចនាហេដ្ឋារចនាសម្ព័ន្ធកម្រិតខ្ពស់ ប៉ាន់ស្មានទំហំទុនវិនិយោគ ពិនិត្យលើការគាំទ្រពីសហគមន៍និងអាជ្ញាធរក្នុងតំបន់ ពិនិត្យលើភាពស្របច្បាប់ និងគណនាពង្រាងជំនួយ ។ ដោយសារនេះជាដំណាក់កាលដំបូងនៃការសិក្សា ក្រុមការងារ CAP-RED នឹងពិនិត្យមើលថាតើអាជីវកម្មនេះជាអាជីវកម្មលក្ខណៈគ្រួសារ ឬអត់។ បើជាអាជីវកម្មលក្ខណៈគ្រួសារ ក្រុមការងារនឹងលើកទឹកចិត្តឱ្យទាំងភរិយា និងស្វាមីចូលរួមក្នុងការពិភាក្សា និងការរចនាបឋមនៃហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត។<br>• ប្រតិបត្តិករ និងអ្នកវិនិយោគទាំងអស់ដែលបំពេញតាមលក្ខខណ្ឌទាំងអស់ក្នុងអំឡុងពេលនៃការសិក្សាសមិទ្ធិលទ្ធភាពបឋមនឹងត្រូវបានការផ្តល់ 'ពង្រាងជំនួយ' |

| សកម្មភាព |
| --- |
| ដែលនឹងបញ្ជាក់ពីចំនួនទឹកប្រាក់នៃការផ្ដល់ជំនួយប្រហាក់ប្រហែលពីកម្មវិធី CAP-RED។ ប្រតិបត្តិករ និងអ្នកវិនិយោគអាចសម្រេចចិត្តថាតើត្រូវបន្តសុំជំនួយទៀត ឬអត់។ |
| **ការសិក្សាសមិទ្ធិលទ្ធភាព៖ ការសិក្សាលម្អិតផ្នែក សង្គម បច្ចេកទេស និងហិរញ្ញវត្ថុ**<br>• កម្មវិធី CAP-RED នឹងជួយប្រតិបត្តិករ និងអ្នកវិនិយោគដែលយល់ព្រមបន្តទៅមុខទៀត បន្ទាប់ពីពិនិត្យពង្រាងជំនួយ ដើម្បីធ្វើការសិក្សាសមិទ្ធិលទ្ធភាពពេញលេញ។ ការសិក្សានេះនឹងរួមបញ្ចូលការសិក្សាផ្នែកសង្គម បច្ចេកទេស ទំហំវិនិយោគ លើហេដ្ឋារចនាសម្ព័ន្ធ (រួមទាំងចំនួនទឹកប្រាក់នៃជំនួយហេដ្ឋារចនាសម្ព័ន្ធពី CAP-RED) និងផែនការវិនិយោគ (រួមទាំងការគណនាតម្លៃលក់ទឹក)។<br>• ការសិក្សានេះ នឹងតម្រូវជាពិសេសឱ្យប្រតិបត្តិករទឹកស្អាត និងអ្នកវិនិយោគ ធ្វើការសម្ភាសន៍ស្ត្រី គ្រួសារក្រីក្រ និងជនពិការដើម្បីកំណត់អំពីកង្វល់ និងទស្សនៈរបស់ពួកគេ ដែលអាចមានជាមួយនឹងគម្រោងវិនិយោគនាពេលខាងមុខ។ |
| **ការស្នើសុំជំនួយវិនិយោគ**<br>• ប្រតិបត្តិករទឹកស្អាត និងអ្នកវិនិយោគត្រូវតែដាក់លិខិតស្នើសុំជំនួយវិនិយោគ ដើម្បីភ្ជាប់ជាមួយរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពលម្អិតទៅគណៈកម្មាធិការត្រួតពិនិត្យរបស់ CAP-RED ដើម្បីសុំការអនុម័តលើថវិកាជំនួយ។ |
| **ការត្រួតពិនិត្យលើសារតា និងផលប៉ះពាល់បរិស្ថាន**<br>• កម្មវិធី CAP-RED នឹងរៀបចំនូវកញ្ចប់សំណើដែលនឹងត្រូវបានត្រួតពិនិត្យគុណភាពដោយគណកម្មការឯករាជ្យរបស់ កម្មវិធី CAP-RED មុនពេលដាក់កញ្ចប់សំណើសម្រាប់ការអនុម័តចុងក្រោយទៅកាន់ម្ចាស់ជំនួយ។ កញ្ចប់សំណើមានរួមបញ្ចូលការសិក្សាសមិទ្ធិលទ្ធភាព សំណើថវិកាជំនួយ ការត្រួតពិនិត្យលើសារតារបស់ប្រតិបត្តិករ និងអ្នកវិនិយោគ និងការវាយតម្លៃផ្នែកបរិស្ថាន។ |
| **ការអនុម័តថវិការជំនួយ**<br>• ដោយផ្អែកលើសំណើសុំជំនួយវិនិយោគ និងអនុសាសន៍របស់ CAP-RED រដ្ឋាភិបាលអូស្ត្រាលី នឹងធ្វើការសម្រេចចិត្តចុងក្រោយលើការអនុម័តជំនួយនេះ។<br>• សម្រាប់ជំនួយដែលមានចំនួនក្រោម ១00,000 ដុល្លារអូស្ត្រាលី CAP-RED នឹងធ្វើការសម្រេចចិត្តចុងក្រោយ។ |

CAP-RED is funded by the Australian Government and implemented by Cowater International.

Address: The iCON Professional Building, 216 Preah Norodom Blvd (41), Phnom Penh
Email: info@capred.org
Tel: 012 817 829

| សកម្មភាព |
| --- |
| • សម្រាប់ជំនួយដែលមានចំនួនស្មើនឹង ឬលើសពី ១00,000 ដុល្លារអូស្ត្រាលី រដ្ឋាភិបាលអូស្ត្រាលីនឹងធ្វើការសម្រេចចិត្តចុងក្រោយ។<br>• ការសម្រេចចិត្តចុងក្រោយអាចមានទម្រង់នៃការអនុម័តដោយគ្មានលក្ខខណ្ឌ ការអនុម័តដោយមានលក្ខខណ្ឌ ឬការបដិសេធមិនយល់ព្រមដោយបញ្ជាក់ហេតុផល។ |
| **ការចុះកិច្ចសន្យា**<br>• ប្រសិនបើសំណើសុំថវិកាជំនួយវិនិយោគត្រូវបានអនុម័ត CAP-RED នឹងធ្វើការចរចាលើកិច្ចសន្យាដោយផ្អែកលើសមិទ្ធផល ជាមួយប្រតិបត្តិករ និងអ្នកវិនិយោគ។ កិច្ចសន្យាដោយផ្អែកលើសមិទ្ធផល បែងចែកការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទៅជាសមិទ្ធផលជាដំណាក់ៗ និងមានការបរិយាយច្បាស់លាស់ពីសមិទ្ធផលនិមួយៗ។ ប្រតិបត្តិករ និងអ្នកវិនិយោគនឹងទទួលបានថវិកាជំនួយដែលបានកំណត់នៅក្នុងកិច្ចសន្យា បន្ទាប់ពីបានបញ្ចប់សមិទ្ធផលនីមួយៗ។ ថវិកាជំនួយនេះនឹងត្រូវបានផ្តល់ជូនជាដុល្លារអូស្ត្រាលី។<br>• កិច្ចសន្យាដោយផ្អែកលើសមិទ្ធផល ក៏នឹងដាក់បញ្ចូលនូវលក្ខខណ្ឌពាក់ព័ន្ធនឹង ការលើកកំពស់សមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (រួមមានការរចនា និងការសាងសង់បង្គន់អនាម័យដាច់ដោយឡែកសម្រាប់ស្ត្រី និងជនពិការ) ជាលក្ខខណ្ឌភ្ជាប់ទៅនឹងការទូទាត់នៃលទ្ធផលជាក់លាក់ណាមួយ ។<br>• ប្រតិបត្តិករ និងអ្នកវិនិយោគអាចធ្វើការសម្រេចចិត្តថាតើត្រូវចុះកិច្ចសន្យាជាមួយ CAP-RED ឬអត់។ |
| **ដំណើរការស្នើសុំប្រកាសអនុញ្ញាតពីក្រសួងឧ.វ.ប.ន.**<br>• ប្រតិបត្តិករទឹកស្អាតឯកជន និងអ្នកវិនិយោគដែលមិនទាន់បានទទួលប្រកាសអនុញ្ញាតពីក្រសួងឧ.វ.ប.ន. ត្រូវតែស្នើសុំប្រកាសអនុញ្ញាត ២0ឆ្នាំ ពី ឧ.វ.ប.ន. សម្រាប់តំបន់សេវាកម្មដែលបានស្នើឡើង។ |
| **ការទូទាត់ប្រាក់ជំនួយ**<br>• បន្ទាប់ពីចុះហត្ថលេខាលើកិច្ចសន្យា ប្រតិបត្តិករទឹក និងអ្នកវិនិយោគ អាចអនុវត្តផែនការវិនិយោគ និងចាប់ផ្តើមសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។<br>• កម្មវិធី CAP-RED តាមរយៈអ្នកប្រឹក្សាឯកទេសនឹងផ្តល់ការបណ្តុះបណ្តាលផ្នែកសុខភាព និងសុវត្ថិភាពការងារ ក៏ដូចជាការបណ្តុះបណ្តាលផ្នែកយេនឌ័រ និងបរិយាបន្នសង្គម។ |

CAP-RED is funded by the Australian Government and implemented by Cowater International.

.

Address: The iCON Professional Building, 216 Preah Norodom Blvd (41), Phnom Penh
Email: info@capred.org
Tel: 012 817 829

| សកម្មភាព |
| --- |
| • កម្មវិធី CAP-RED នឹងធ្វើការចុះត្រួតពិនិត្យក្នុងអំឡុងពេលសាងសង់ ដើម្បីវាយតម្លៃពីវឌ្ឍនភាព ក៏ដូចជាផលប៉ះពាល់អវិជ្ជមាននានា ដែលកើតចេញពីការសាងសង់ ទៅលើសហគមន៍ ជាពិសេសទាក់ទងនឹងស្ត្រី កុមារី ជនពិការ និងក្រុមងាយរងគ្រោះ និងជនជាតិភាគតិច។<br>• ការប្រគល់ថវិកាជំនួយទៅប្រតិបត្តិករ និងអ្នកវិនិយោគគឺផ្អែកលើការបញ្ចប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលបានរៀបរាប់នៅក្នុងកិច្ចសន្យាផ្អែកលើសមិទ្ធផលហើយមានលក្ខខណ្ឌតម្រូវឱ្យប្រតិបត្តិករ និងអ្នកវិនិយោគត្រូវទទួលបានប្រកាសអនុញ្ញាតរយៈពេល ២០ឆ្នាំពី ក្រសួងឧ.វ.ប.ន. សម្រាប់តំបន់សេវាកម្មដែលបានស្នើឡើង។ |

## ៥. លក្ខខណ្ឌក្នុងការចូលរួម

ខាងក្រោមនេះគឺជាលក្ខខណ្ឌដែលត្រូវមានសម្រាប់ការដាក់ស្នើសុំជំនួយជុំទីមួយរបស់ CAP-RED៖

១. តំបន់សេវាកម្មដែលស្នើសុំជំនួយត្រូវតែនៅក្នុង **ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង** ឬ **ខេត្តតាកែវ** ។

២. ប្រតិបត្តិករទឹកស្អាតឯកជន ឬអ្នកវិនិយោគត្រូវតែ៖

- កំពុងផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ក្នុងតំបន់សេវាកម្មដែលមិនស្ថិតក្រោមប្រកាសអនុញ្ញាតរបស់អ្នកដទៃ ឬ
- កំពុងដាក់របាយការណ៍សិក្សាសមិទ្ធិលទ្ធភាពរួចរាល់ទៅកាន់ក្រសួងឧ.វ.ប.ន. ឬ
- បានទទួលលិខិតអនុញ្ញាតដើម្បីធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៅតំបន់សេវាកម្មនោះពី ក្រសួងឧ.វ.ប.ន. ត្រឹម **ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២។**

៣. ប្រតិបត្តិករទឹកស្អាតឯកជន និងអ្នកវិនិយោគ ត្រូវតែប្តេជ្ញាចិត្តក្នុងការសាងសង់ ឬកែលម្អបរិក្ខារហេដ្ឋារចនាសម្ព័ន្ធផលិតទឹកស្អាតដល់កម្រិតមួយដែលវាអាចផលិតទឹកស្អាតប្រកបដោយគុណភាពស្របតាមលក្ខខណ្ឌតម្រូវរបស់ប្រកាស ក្រសួងឧ.វ.ប.ន.។

៤. ប្រតិបត្តិករ និងអ្នកវិនិយោគដែលមិនទាន់បានទទួលប្រកាសអនុញ្ញាត ២០ឆ្នាំពី ក្រសួងឧ.វ.ប.ន. ត្រូវតែប្តេជ្ញាក្នុងការស្នើសុំប្រកាសអនុញ្ញាត ២០ឆ្នាំសម្រាប់តំបន់សេវាកម្មដែលបានស្នើឡើង ហើយត្រូវតែបង្ហាញភស្តុតាងនៃការស្នើសុំប្រកាសអនុញ្ញាត។

៥. ចំនួនគ្រួសារសរុបនៅក្នុងភូមិដែលមិនទាន់មានបណ្តាញទុយោក្នុងតំបន់សេវាកម្មដែលសុំជំនួយចាប់ពី **២.០០០គ្រួសារ** និងតិចជាងពី **១០.០០០គ្រួសារ**។

៦. ប្រតិបត្តិករ និងអ្នកវិនិយោគត្រូវតែបង្ហាញពីបទពិសោធន៍អាជីវកម្មដោយបំពេញឱ្យបានយ៉ាងហោចណាស់លក្ខខណ្ឌមួយក្នុងចំណោមខាងក្រោម៖

- ត្រូវតែមានបទពិសោធន៍យ៉ាងតិចមួយឆ្នាំក្នុងនាមជាម្ចាស់ក្រុមហ៊ុនសេវាកម្មទឹកស្អាតតាមបំពង់; ឬ
- ត្រូវតែមានបទពិសោធន៍យ៉ាងតិចពីរឆ្នាំនៅក្នុងអាជីវកម្មទឹកស្អាតតាមបំពង់ ឬអាជីវកម្មដែលពាក់ព័ន្ធផ្សេងទៀត (ប៉ុន្តែមិនរាប់បញ្ចូលហាងលក់រាយលក្ខណៈតូចទេ); ឬ
- ត្រូវមានលិខិតគាំទ្រពីមិត្តភក្តិ មិត្តរួមការងារ ឬសាច់ញាតិដែលជាម្ចាស់ ឬអ្នកដែលមានបទពិសោធន៍យ៉ាងតិចមួយឆ្នាំក្នុងអាជីវកម្មទឹកស្អាតតាមបំពង់។

៧. ប្រតិបត្តិករ និងអ្នកវិនិយោគត្រូវតែបង្ហាញពីបទពិសោធន៍បច្ចេកទេសដោយបំពេញឱ្យបានយ៉ាងហោចណាស់មួយក្នុងចំណោមខាងក្រោមនេះ៖
- ត្រូវតែមានបទពិសោធន៍ក្នុងការធ្វើជាម្ចាស់ និងប្រតិបត្តិការអាជីវកម្មទឹកស្អាតតាមបំពង់; ឬ
- ត្រូវតែមានបុគ្គលិកដែលមានបទពិសោធន៍ក្នុងអាជីវកម្មទឹកស្អាតតាមបំពង់; ឬ
- ត្រូវតែមានផែនការបណ្តុះបណ្តាល និងអភិវឌ្ឍជំនាញរបស់អ្នកគ្រប់គ្រង និងបុគ្គលិកណាមួយ។

៨. ប្រតិបត្តិករ និងអ្នកវិនិយោគត្រូវតែបង្ហាញពីកិច្ចសហការ និងការគាំទ្រពីអាជ្ញាធរមូលដ្ឋាន និងអ្នកប្រើប្រាស់ទឹក។

៩. ប្រតិបត្តិករ និងអ្នកវិនិយោគត្រូវតែប្តេជ្ញាក្នុងការទទួលយកការពង្រឹងយេនឌ័រ នៅក្នុងដំណើរការការងាររបស់ខ្លួន និងក្នុងចំណោមបុគ្គលិករបស់ខ្លួន ហើយមានឆន្ទៈក្នុងការសហការជាមួយ CAP-RED ដើម្បីផ្តល់ឱ្យកម្មករ និងបុគ្គលិករបស់ខ្លួននូវការបណ្តុះបណ្តាលទាក់ទងនឹងយេនឌ័រ។

១០. ប្រភពទឹកដែលបានស្នើឡើងត្រូវតែអាចផ្គត់ផ្គង់ទឹកដល់គ្រប់គ្រួសារក្នុងតំបន់សេវាកម្មបានពេញមួយឆ្នាំ។ ករណីប្រភពទឹកមិនអាចផ្គត់ផ្គង់ទឹកពេញមួយឆ្នាំ ប្រតិបត្តិករទឹកស្អាតឯកជន និងអ្នកវិនិយោគត្រូវបង្ហាញពីដំណោះស្រាយចំពោះបញ្ហានេះ។

**គម្រោងដែលប្រើប្រាស់ទឹកក្រោមដីជាប្រភពទឹក មិនត្រូវតាមលក្ខខណ្ឌចូលរួមក្នុងជុំជំនួយនេះទេ។ ប្រសិនបើគម្រោងដែល CAP-RED គណនាតាមបែបជលសាស្ត្រ ហើយតម្រូវឱ្យមានការ ជីកស្រះបន្ថែមដែលមានសមត្ថភាពស្តុកទឹកលើកពីរយៈពេល៣ខែ នៃតម្រូវការទឹកនៅឆ្នាំទី៥ គឺមិនត្រូវលក្ខខណ្ឌចូលរួមជុំជំនួយនេះទេ។**

**ចំណាំ៖ រាល់អំណះអំណាងលើលក្ខខណ្ឌខាងលើនឹងត្រូវពិនិត្យផ្ទៀងផ្ទាត់ក្នុងពេលសិក្សាសមិទ្ធិលទ្ធភាព និងក្នុងពេលវាយតម្លៃពីភាពស្របច្បាប់របស់ប្រតិបត្តិករនិងអ្នកវិនិយោគ។*

## ៦. លក្ខខណ្ឌក្នុងការផ្តល់ជំនួយ

ខាងក្រោមនេះជាលក្ខខណ្ឌក្នុងការផ្តល់ជំនួយ៖

- អ្នកដាក់ពាក្យត្រូវតែបានទទួលប្រកាសអនុញ្ញាតពីក្រសួងឧ.វ.ប.ន. ។

CAP-RED is funded by the Australian Government and implemented by Cowater International.

Address: The iCON Professional Building, 216 Preah Norodom Blvd (41), Phnom Penh
Email: info@capred.org
Tel: 012 817 829

- អ្នកដាក់ពាក្យត្រូវតែយល់ព្រមលើទំហំនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធតាមការសិក្សាសមិទ្ធិលទ្ធភាពសម្រាប់ទីតាំងនីមួយៗដែលធ្វើឡើងដោយ CAP-RED។
- អ្នកដាក់ពាក្យត្រូវតែយល់ព្រមតាមកាលវិភាគនៃសមិទ្ធផលផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដូចដែលបានស្នើឡើងដោយ CAP-RED។
- អ្នកដាក់ពាក្យត្រូវតែទទួលយក និងអនុវត្តតាមលក្ខខណ្ឌកិច្ចសន្យាដែលផ្តល់ដោយ CAP-RED។
- អ្នកដាក់ពាក្យត្រូវតែទទួលយកនូវ ក្រមសីលធមអាជីវកម្មរបស់ក្រុមហ៊ុន Cowater ដែលភ្ជាប់មកជាមួយ និងក្រមសីលធមិពិសេសផ្សេងទៀតដែលប្តេជ្ញាដោយក្រុមហ៊ុនក្នុងការសាងសង់ និងប្រតិបត្តិការគម្រោងនេះជាអាជីវកម្មស្របច្បាប់។
- អ្នកដាក់ពាក្យត្រូវតែគោរពតាមលក្ខណៈបច្ចេកទេសសំណង់ដែលបានព្រមព្រៀងជាមុន។

## ៧. មូលដ្ឋានសម្រាប់ការគណនាជំនួយ

ខាងក្រោមនេះគឺជាមូលដ្ឋានក្នុងការគណនាថវិកាជំនួយរបស់ CAP-RED សម្រាប់គម្រោងទឹកស្អាតតាមបំពង់នីមួយៗ៖

១. ប្រសិនមិនមានជំនួយ រយៈពេលនៃការសងត្រឡប់របស់ការវិនិយោគក្នុងទីតាំងដែលស្នើសុំគឺលើស ៧ឆ្នាំ។ CAP-REDនឹងផ្តល់ជំនួយដើម្បីទាញរយៈពេលនៃការសងត្រឡប់អោយស្មើរ **៧ឆ្នាំ**។

២. ទំហំជំនួយដែល CAP-RED ផ្តល់ជូនមិនលើសពី **៦៥ ដុល្លារ** ក្នុងមួយគ្រួសារទេ។

៣. អត្រាសមាមាត្រនៃជំនួយរបស់ CAP-REDធៀបនឹងទុនវិនិយោគសរុបមិនឲ្យលើសពី **៦០%** ទេ។

៤. ជំនួយវិនិយោគអតិបរមាត្រូវបានកំណត់ត្រឹម **២៥០,000** ដុល្លារអាមេរិក សម្រាប់គម្រោងនិមួយៗដែលបំពេញតាមលក្ខខណ្ឌផ្តល់ជំនួយ។

៥. កម្មវិធី CAP-RED នឹងផ្តល់ជំនួយសម្រាប់ការតភ្ជាប់បណ្តាញសម្រាប់តែភូមិណាដែលមិនទាន់មានបណ្តាញទុយោទឹក គិតត្រឹមថ្ងៃដែលចុះហត្ថលេខាកិច្ចសន្យាជាមួយកម្មវិធី CAP-RED ។ ជំនួយសំរាប់ការតភ្ជាប់បណ្តាញ គឺ **៣៥ ដុល្លារអាមេរិក** ក្នុងមួយតំណសំរាប់គ្រួសារដែលមានបណ្ណក្រីក្រ និង **៧៥ ដុល្លារអាមេរិក** ក្នុងមួយតំណសំរាប់សាលារៀន ឬមណ្ឌលសុខភាព។

## ៨. កាលបរិច្ឆេទសំខាន់ៗ

ការស្នើសុំជំនួយ ការវាយតម្លៃ និងដំណើរការអនុម័តនឹងមានពេលវេលាដូចខាងក្រោម៖

| សកម្មភាព | កាលបរិច្ឆេទ/រយៈពេល |
|---|---|
| ប្រកាសបើកជំនួយជុំទី ១ | ថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០២២ |

CAP-RED is funded by the Australian Government and implemented by Cowater International.

.

Address: The iCON Professional Building, 216 Preah Norodom Blvd (41), Phnom Penh
Email: info@capred.org
Tel: 012 817 829

| សកម្មភាព | កាលបរិច្ឆេទ/រយៈពេល |
|---|---|
| សិក្ខាសាលាផ្តល់ព័ត៌មានលម្អិតពីលក្ខខណ្ឌផ្តល់ជំនួយ | ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០២២ ម៉ោង ០៩:00 ព្រឹក នៅមន្ទីឧ.វ.ប.ន. នៃ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តតាកែវ។ |
| ថ្ងៃផុតកំណត់ក្នុងការដាក់ពាក្យស្នើសុំជំនួយ | ថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០២២ |
| វាយតម្លៃលើពាក្យស្នើសុំជំនួយ | រយៈពេល ៣ខែ បន្ទាប់ពីទទួលបានព័ត៌មានដែលត្រូវការ ទាំងអស់។ |
| សិក្សាសមិទ្ធិលទ្ធភាពបឋម | |
| ការផ្តល់ជូនពង្រាងជំនួយ | |
| សិក្សាសមិទ្ធិលទ្ធភាពលម្អិត និងផែនការបច្ចេកទេសផ្សេងៗ | |
| របាយការណ៍ជាអនុសាសន៍ពីកម្មវិធី CAP-RED សម្រាប់ការផ្តល់ជំនួយ | រយៈពេល ១អាទិត្យ បន្ទាប់ពីបញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាពលម្អិត |
| ការដាក់លិខិតស្នើសុំជំនួយវិនិយោគពីប្រតិបត្តិករទឹក និងអ្នកវិនិយោគ និងរបាយការណ៍ជាអនុសាសន៍ពី CAP-RED ជូនគណៈកម្មាធិការត្រួតពិនិត្យថវិកាជំនួយ | រយៈពេល ២ថ្ងៃ បន្ទាប់ពីទទួលបានឯកសារទាំងអស់ |
| គណៈកម្មាធិការត្រួតពិនិត្យជំនួយឬរដ្ឋាភិបាលអូស្ត្រាលី ធ្វើការសំរេចលើកចុងក្រោយទៅលើការអនុម័តផ្តល់ថវិកាជំនួយ | រយៈពេល ៣ ទៅ ៤អាទិត្យ បន្ទាប់ពីទទួលបានឯកសារ |
| ការប្រកាសអំពីការផ្តល់ជំនួយទៅប្រតិបត្តិករ និងអ្នកវិនិយោគ | មួយអាទិត្យក្រោយពីមានការសំរេចលើកចុងក្រោយពីគណៈកម្មាធិការត្រួតពិនិត្យថវិកាជំនួយ ឬរដ្ឋាភិបាលអូស្ត្រាលី |
| ការចរចារកិច្ចសន្យាផ្អែកលើសមិទ្ធផលជាមួយប្រតិបត្តិករ និងអ្នកវិនិយោគ និងការចុះកិច្ចសន្យា។ | អាស្រ័យទៅលើរយៈពេលនៃការចរចារ។ ជាទូទៅចំណាយពេលមួយខែ ដើម្បីភាគីទាំងសងខាងចុះកិច្ចសន្យា។ |

CAP-RED is funded by the Australian Government and implemented by Cowater International.

Address: The iCON Professional Building, 216 Preah Norodom Blvd (41), Phnom Penh
Email: info@capred.org
Tel: 012 817 829

## ៩. វិធីក្នុងការដាក់ពាក្យស្នើសុំ

ពាក្យស្នើសុំជំនួយអាចបំពេញជាភាសាខ្មែរ ឬភាសាអង់គ្លេស និងដាក់ជូនជាច្បាប់រឹង ឬជាឯកសារអេឡិចត្រូនិច ។

ពាក្យស្នើសុំជំនួយដែលបំពេញរួចត្រូវដាក់អោយបានត្រឹម **ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២** តាមអាស័យដ្ឋានដូចខាងក្រោម៖

**អាស័យដ្ឋាន៖** ជាន់ទី ៥ នៃអគារ ICON Professional អគារលេខ 126 មហាវិថីនរោត្តម រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

**អ៊ីមែល៖** *info@capred.org*

**Telegram:** 012 817 829

ទម្រង់ពាក្យសុំជំនួយក៏អាចទាញយកបានពី Telegram Group: CAP-RED EoI Round 1

## ១០. ទំនាក់ទំនង

រាល់សំនួរដែលទាក់ទងនឹងដំណើការជ្រើសរើស និងការផ្តល់ជំនួយអាចទាក់ទងមកកាន់លេខ **០១២ ៨១៧ ៨២៩** ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពីម៉ោង៨:០០នាទីព្រឹកដល់ម៉ោង៥:០០នាទីល្ងាច។

រាល់សំនួរ និងចំលើយពាក់ព័ន្ធនឹងដំណើរការជ្រើសរើសនិងផ្តល់ជំនួយនឹងត្រូវបានបង្ហោះនៅលើ CAP-RED Telegram Group។